**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.៣៣៦......សហវ.....២

# សេចក្ដីណែនាំ

## ស្ដីពី

## នីតិវិធី និងបែបបទនៃការពិនិត្យ វាយតម្លៃលក្ខណសម្បត្តិផ្ដល់គ្រឿងឥស្សរិយយស និងមេដាយការងារ ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ដើម្បីជាការលើកទឹកចិត្ត ព្រមទាំងចារឹកទុកនូវគុណបំណាច់ និងស្នាដៃដ៏ខ្ពង់ខ្ពស់ របស់មន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការរួមចំណែកកសាង និងអភិវឌ្ឍប្រទេស ស្របតាមទំហំស្នាដៃរបស់បុគ្គលម្នាក់ៗ និងដោយគោរពតាមខ្លឹមសារព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា អនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០០ ស្ដីពីការបង្កើតគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស សារាចរណែនាំលេខ ០១ សរណន ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០០១ របស់រាជរដ្ឋាភិបាល ស្ដីពីការរៀបចំបែបបទស្នើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា និង ប្រកាសលេខ ១០៨ សហវ.ប្រកប ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការបង្កើតគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវស្នើសុំគ្រឿងឥស្សរិយយស និង មេដាយការងារ ក្រសួងសូមធ្វើការណែនាំដល់គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាព មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរាជធានី-ខេត្ត ក្រោមឱវាទ អំពីនីតិវិធី និងបែបបទ នៃការពិនិត្យ និងវាយតម្លៃ ផ្ដល់គ្រឿងឥស្សរិយយស និងមេដាយការងារ ដូចខាងក្រោម៖



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

១- គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាព មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត ក្រោមឱវាទក្រសួង ត្រូវបង្កើតឱ្យមានគណៈកម្មការពិនិត្យ និងវាយតម្លៃលក្ខណសម្បត្តិបេក្ខជន ដែលត្រូវរៀបចំ និងមានសមាសភាពដូចខាងក្រោម ៖

**ក- អគ្គនាយកដ្ឋាន** សមាសភាព រួមមានៈ

| | |
|---|---|
| - អគ្គនាយក | ប្រធាន |
| - អគ្គនាយករង | សមាជិក |
| - ប្រធាននាយកដ្ឋានទទួលបន្ទុកការងារបុគ្គលិក | សមាជិកអចិន្ត្រៃយ៍ |

នាយកដ្ឋាន និងសាខា/អង្គភាពចំណុះអគ្គនាយកដ្ឋាន ត្រូវរៀបចំគណៈកម្មការពិនិត្យ និងវាយតម្លៃលក្ខណសម្បត្តិបេក្ខជន ដែលមានសមាសភាពដូចបានកំណត់ក្នុងចំណុច **ខ** និង **គ** ខាងក្រោម ។ បញ្ជីឈ្មោះបេក្ខជនរបស់នាយកដ្ឋាន និងសាខា/អង្គភាព ត្រូវបញ្ជូនមកនាយកដ្ឋានទទួលបន្ទុកកិច្ចការបុគ្គលិករបស់អគ្គនាយកដ្ឋានដើម្បីបូកសរុប និងធ្វើរបាយការណ៍ជាក់ជូនគណៈកម្មការអគ្គនាយកដ្ឋានពិនិត្យ និងសម្រេច មុននឹងបញ្ជូនមកនាយកដ្ឋានបុគ្គលិកនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ខ- នាយកដ្ឋានៈ** សមាសភាព រួមមានៈ

| | |
|---|---|
| - ប្រធាននាយកដ្ឋាន | ប្រធាន |
| - អនុប្រធាននាយកដ្ឋាន | សមាជិក |
| - ប្រធានការិយាល័យ | សមាជិក |

**គ- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ /សាខា/អង្គភាពចំណុះអគ្គនាយកដ្ឋាននៅរាជធានី-ខេត្ត**

សមាសភាព រួមមានៈ

| | |
|---|---|
| - ប្រធានមន្ទីរ/សាខា/អង្គភាព | ប្រធាន |
| - អនុប្រធានមន្ទីរ/សាខា/អង្គភាព | សមាជិក |
| - ប្រធានការិយាល័យ/ទីស្នាក់ការ | សមាជិក |

២- ការវាយតម្លៃបេក្ខជន ត្រូវផ្អែកលើលក្ខណសម្បត្តិដូចខាងក្រោមៈ

- សីលធម៌រស់នៅស្អាតស្អំ មិនប្រព្រឹត្តអំពើពុករលួយ និង សកម្មភាពផ្ទុយពីច្បាប់រដ្ឋ
- គំនិតផ្តួចផ្តើម និង មនសិការវិជ្ជាជីវៈខ្ពស់ សកម្មការងារ ឧស្សាហ៍ព្យាយាម ច្នៃប្រឌិត និងទទួលខុសត្រូវខ្ពស់
- ការដឹកនាំ និងគ្រប់គ្រងមានប្រសិទ្ធភាព
- ស្មារតីស្នេហាជាតិ គិតគូរដល់ផលប្រយោជន៍ជាតិ និងកិត្តិយសរបស់អង្គភាព ក្រសួង
- សាមគ្គីភាព និងទំនាក់ទំនងល្អជាមួយមហាជនទូទៅ ។

៣- គណៈកម្មការខាងលើ មានភារកិច្ចប្រជុំពិនិត្យ និងវាយតម្លៃលក្ខណសម្បត្តិមន្ត្រីរាជការក្រោមឱវាទ សម្រាប់ជ្រើសរើសជាបេក្ខជន ដើម្បីស្នើសុំគ្រឿងឥស្សរិយយស និងមេដាយការងារ ទៅតាមប្រភេទ និងវិស័យការងារ ស្របតាមខ្លឹមសារដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកតាមលំដាប់នៃគ្រឿងឥស្សរិយយស និងមេដាយការងារ ដែលធ្លាប់បានទទួលកន្លងមកក្នុងក្របខ័ណ្ឌការងារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ចំនួនបេក្ខជនប្រចាំឆ្នាំនៃបណ្តាអគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាព និង មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត ត្រូវកំណត់មិនឱ្យលើស ១០% នៃចំនួនក្របខ័ណ្ឌសរុបរបស់អង្គភាពនីមួយៗ និងឆ្លាស់វេនគ្នារយៈពេល ២ ឆ្នាំម្តង ។

គណកម្មការ អាចធ្វើការពិនិត្យវាយតម្លៃ និងលើកសំណើ ជាករណីពិសេស ដើម្បីស្នើសុំគ្រឿងឥស្សរិយយស និងមេដាយការងារ ផ្តល់ជូនដល់មន្ត្រីរាជការដែលមានស្នាដៃឆ្នើមលេចធ្លោ មន្ត្រីទទួលមរណភាព ឬ បាត់បង់សម្បទាវិជ្ជាជីវៈក្នុងបេសកកម្មការងារ និងមន្ត្រីដែលមានស្នាដៃការងារជាច្រើនឆ្នាំហើយត្រូវដល់អាយុចូលនិវត្តន៍ ។

៤- អគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាព និង មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត ត្រូវបញ្ជូនបញ្ជីឈ្មោះបេក្ខជន មកនាយកដ្ឋានបុគ្គលិក នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី ៣១ ខែ កក្កដា នៃឆ្នាំនីមួយៗ ដោយភ្ជាប់មកជាមួយនូវកំណត់ហេតុប្រជុំវាយតម្លៃរបស់គណៈកម្មការនីមួយៗ ។

៥- នាយកដ្ឋានបុគ្គលិក នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធ្វើការបូកសរុប និងធ្វើរបាយការណ៍ជាក់ជូនគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវស្នើគ្រឿងឥស្សរិយយស និងមេដាយការងារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី ៣១ ខែ សីហា នៃឆ្នាំនីមួយៗ ដើម្បីពិនិត្យ និងសម្រេច ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមថា គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាព មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត ក្រោមឱវាទក្រសួង នឹងចាត់ចែងអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះ ប្រកបដោយស្មារតីយកចិត្តទុកដាក់ខ្ពស់ សំដៅរក្សាបាននូវសុក្រឹតភាព និង តម្លៃនៃគ្រឿងឥស្សរិយយស និងមេដាយការងាររបស់ជាតិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន:**

-ឯកឧត្តមរដ្ឋលេខាធិការ / អនុរដ្ឋលេខាធិការ
-ឯកឧត្តមអគ្គលេខាធិការ / អគ្គលេខាធិការរង
« ដើម្បីជូនជ្រាប »
-គ្រប់អគ្គនាយកដ្ឋាន ព្រមទាំងសាខាគយ និងរដ្ឋាករ សាខាពន្ធដារ រតនាគាររាជធានី ខេត្ត នាយកដ្ឋាន មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត និងអង្គភាពក្រោមឱវាទក្រសួង
« ដើម្បីផ្សព្វផ្សាយ និងអនុវត្ត »
-ឯកសារ-កាលប្បវត្តិ